**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៩០៣ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤

# ប្រកាស

## ស្តីពី

## ការផ្ទេរឥណទានថវិកា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៣៦អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៣៣៧អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការផ្ទេរឥណទានថវិកា
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

**ប្រការ១.-**

ត្រូវបានប្រតិបត្តិនៅក្នុងវង្ង់ថវិកាបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ នូវការផ្ទេរឥណទានថវិកាដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

**ក-និយ័តកម្មចេញពី ៩៩ (ចំណាយមិនទាន់បែងចែកមានមុខសញ្ញា)**

ឯកតា លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|
| | | | | | កើន | ថយ | |
| | | | **និយ័តកម្មចេញ** | | | 1 132 301 | |
| | | | **៩៩ - ចំណាយមិនទាន់បែងចែក** | | | 1 132 301 | |
| ៦៦ | | | បន្ទុកហិរញ្ញវត្ថុ(ការប្រាក់) | 276 381 | - | 276 381 | 0 |
| ៦៥ | | | ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុកនិងឃុំ សង្កាត់ | 442 896 | - | 386 952 | 55 944 |
| ៥០ | | | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 436 568 | - | 436 568 | 0 |
| ២៧ | | | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 32 400 | - | 32 400 | 0 |
| | | | **និយ័តកម្មចូល** | | 1 132 301 | | |
| | | | **១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | | 1 132 301 | | |
| ៦៦ | | | បន្ទុកហិរញ្ញវត្ថុ(ការប្រាក់) | 0 | 276 381 | - | 276 381 |
| ៦៥ | ៦៥០១ | ៦៥០១១ | ឧបត្ថម្ភកធនដល់រាជធានី ខេត្ត | 0 | 37 297 | - | 37 297 |
| ៦៥ | ៦៥០១ | ៦៥០១២ | ឧបត្ថម្ភកធនដល់ក្រុង ស្រុក ខណ្ឌ | 0 | 77 701 | - | 77 701 |
| ៦៥ | ៦៥០១ | ៦៥០១៣ | ឧបត្ថម្ភកធនដល់ឃុំ សង្កាត់ | 0 | 271 954 | - | 271 954 |
| ៥០ | | | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 0 | 436 568 | - | 436 568 |
| ២៧ | ២៧០១ | ២៧០១១ | ការឲ្យខ្ចី ទៅសហគ្រាសសាធារណៈ | 0 | 32 400 | - | 32 400 |

**ប្រការ២.-**

ឥណទានថវិកាដែលបានផ្ទេរក្នុងប្រការ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឲ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**ប្រការ៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន**

- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ